សេចក្តីថ្លែងការណ៍រួម
ស្តីពីការរឹតត្បិតសិទ្ធិសេរីភាពខាងការជួបជុំទីសាធារណៈដោយសន្តិវិធី

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៦

យើងខ្ញុំជាតំណាងអង្គការសង្គមស៊ីវិល សមាគម និងសហជីព ដែលមានរាយនামខាងក្រោម មានការសោកស្តាយជាខ្លាំង ដែលសាលារាជធានីភ្នំពេញ មិនអនុញ្ញាតឱ្យយើងខ្ញុំរៀបចំកម្មវិធីរំលឹកខួបកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ខួបលើកទី៣៥ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៦ នៅសួនច្បារក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ការរឹតត្បិតដែលមិនសមហេតុផលនេះ គឺជាការរំលោភសិទ្ធិសេរីភាពខាងការជួបជុំ និងបញ្ចេញមតិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ និងមិនស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាសាលារាជធានីភ្នំពេញទទួលបានការជូនដំណឹងជាមុនរួចហើយក៏ដោយ។

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ២៣ ខែតុលា ឆ្នាំ១៩៩១ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏សំខាន់ ដែលនាំប្រទេសជាតិឆ្ពោះទៅរកសន្តិភាព ការផ្សះផ្សារជាតិ ការស្តារ និងការអភិវឌ្ឍស្រមតាមសង្គមប្រជាធិបតេយ្យសេរីពហុបក្ស ដោយផ្អែកលើការគោរពសិទ្ធិមនុស្ស នីតិរដ្ឋ និងអធិបតេយ្យភាពរបស់កម្ពុជានៅលើឆាកអន្តរជាតិ។ ដូច្នេះ ការរំលឹកខួប គឺជាឱកាសមួយដែលប្រជាពលរដ្ឋកម្ពុជា អាចជួបជុំគ្នា បញ្ចេញមតិ និងលើកឡើងអំពីការវិវឌ្ឍ និងការសម្រេចបាននូវគោលបំណងដើមនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស អំពីសន្តិភាព សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍសង្គម ។ មិនតែប៉ុណ្ណោះ ទិវានេះក៏ជាឱកាសដ៏មានសារៈសំខាន់ក្នុងការបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរបស់យើងទាំងអស់គ្នា ក្នុងការបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួន ចំពោះកិច្ចព្រមព្រៀងនេះ ។

អាជ្ញាធររដ្ឋកាន់តែបង្កើនការរឹតត្បិតសិទ្ធិសេរីភាពខាងការជួបជុំដោយសន្តិវិធីនៅទីសាធារណៈ ជាពិសេសនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលរួមទាំងការរឹតត្បិតចុងក្រោយដែលបានកើតឡើងក្នុង ឱកាសនៃការរំលឹកខួបនេះ។ ការរឹតត្បិតនេះ ធ្វើឱ្យលំហនៃការអនុវត្តសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ដែលកំពុងរួមតូចស្រាប់ឱ្យកាន់តែលែងមាននៅក្នុងសង្គមកម្ពុជា ជាពិសេសសេរីភាពខាងការជួបជុំដោយផ្ទាល់នៅតាមទីសាធារណៈ ដើម្បីបញ្ចេញមតិ ឬកង្វល់របស់ពួកគេ ។ សកម្មភាពរឹតត្បិតទាំងនេះ គឺជាការអនុវត្តផ្ទុយនឹងរដ្ឋធម្មនុញ្ញកម្ពុជាហើយ ចាកឆ្ងាយកាន់តែខ្លាំងពីគោលបំណងនៃកិច្ចព្រមព្រៀងសន្តិភាពនៃទីក្រុងប៉ារីស ។

ខណៈដែលប្រទេសកម្ពុជា តែងតែប្រកាសជាសាធារណៈ និងចំពោះអន្តរជាតិថា រាជរដ្ឋាភិបាលបានធានានូវការគោរពយ៉ាងពេញលេញនូវសិទ្ធិមនុស្ស ដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ កតិកាសញ្ញា អនុសញ្ញា និងលិខិតតូបករណ៍ពាក់ព័ន្ធនានា រួមទាំងសិទ្ធិស្ត្រី និងកុមារ ប៉ុន្តែអាជ្ញាធរតែងតែបដិសេធម្តងហើយម្តងទៀត ចំពោះការជួបជុំដោយសន្តិវិធីនានានៅទីសាធារណៈ ។

លំហសេរីភាពសាធារណៈដែលបានរួមតូច ធ្វើឱ្យសំឡេងរបស់ប្រជាពលរដ្ឋ ជាពិសេសក្រុមងាយរងគ្រោះ និងអ្នកដែលរងផលប៉ះពាល់ពីភាពអយុត្តិធម៌ក្នុងសង្គម មិនត្រូវបានស្តាប់ឮ ឬយកចិត្តទុកដាក់គ្រប់គ្រាន់។ ស្ថាន

ភាពដ៏អាក្រក់នេះ នឹងរារាំងការអភិវឌ្ឍន៍ប្រទេសជាតិ ប្រកបដោយបរិយាប័ន្ន ពហុភាពនិយម និងសមធម៌ ក៏ដូចជារារាំងកម្ពុជាក្នុងការសម្រេចបាននូវទស្សនវិស័យ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ យើងខ្ញុំជាអង្គការសង្គមស៊ីវិល សូមអំពាវនាវយ៉ាងទទូចដល់សាលារាជធានីភ្នំពេញ និងអាជ្ញាធរពាក់ព័ន្ធ ត្រូវបញ្ឈប់រាល់រូបភាពនៃការរឹតត្បិត ឬបំបិទសិទ្ធិសេរីភាពសម្តែងមតិ និងការជួបជុំសាធារណៈដោយសន្តិវិធីរបស់ប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល ដោយត្រូវធានានូវ ការអនុវត្តសិទ្ធិសេរីភាពទាំងនេះឱ្យបានពេញលេញ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ។

យើងខ្ញុំសូមបញ្ជាក់ជាថ្មីថា ការការពារសិទ្ធិសេរីភាព និងការបើកទូលាយលំហសាធារណៈ គឺជាការទទួលខុសត្រូវរួមរបស់រដ្ឋ សង្គមស៊ីវិល និងប្រជាពលរដ្ឋគ្រប់រូប។ យើងខ្ញុំនឹងបន្តចូលរួមដោយសន្តិវិធី និងស្របតាមច្បាប់ ដើម្បីលើកកម្ពស់សិទ្ធិមនុស្ស យុត្តិធម៌សង្គម លទ្ធិប្រជាធិបតេយ្យ និងសន្តិភាពពិតប្រាកដនៅកម្ពុជា។ សន្តិភាពពិតប្រាកដ ត្រូវដើរទន្ទឹមនឹងសេរីភាព យុត្តិធម៌ និងការគោរពសិទ្ធិមនុស្ស ។

ឈ្មោះអង្គការ សមាគម និងសហជីពដែលគាំទ្រសេចក្តីថ្លែងការណ៍រួម៖

១- សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)

២- អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)

៣- សហព័ន្ធសហជីពកម្ពុជាឯករាជ្យ

៤- សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)

៥- អង្គការមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)

៦- អង្គការមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)

៧- អង្គការគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា (COMFREL)

៨- អង្គការមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)

៩- សមាគមបណ្តាញយុវជនកម្ពុជា (CYN)

១០- សហព័ន្ធសហជីពវិស័យទេសចរណ៍

១១- អង្គការលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍ (CMPO)

១២- អង្គការមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)

១៣- សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា

១៤- សម្ព័ន្ធសហជីពកាត់ដេរសម្លៀកបំពាក់ និងឧស្សាហកម្ម

១៥- សហព័ន្ធសហជីពអំណាចយុវជនកម្ពុជា

១៦- ក្រុមពង្រឹងសិទ្ធិអំណាចយុវជនដើម្បីសមធម៌សង្គម

១៧- សហព័ន្ធសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា

១៨- សហព័ន្ធសហជីពឥទ្ធិពលការងារ

១៩- សហព័ន្ធសហជីពឯករាជ្យ

២០- អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)

២១- អង្គការមជ្ឈមមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព

២២- អង្គការសមាគមធាងត្នោត (STT)

២៣- អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍ

២៤- សហព័ន្ធសហជីពបេះដូងកម្មករ

២៥- សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍ សេវាកម្មកម្ពុជា

២៦- សមាគមខ្មែរនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

២៧- សមាគមកសិករដើម្បីសន្តិភាព និងអភិវឌ្ឍន៍

២៨- សហព័ន្ធសហជីពកម្មករនិយោជិតវិស័យឧស្សាហកម្មកម្ពុជា

២៩- សមាគមអ្នកបើកបររថយន្តធុនធ្ងន់កម្ពុជា